ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២៧ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រ ការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៦ នៃរដ្ឋសភា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា **នៅខេត្តកំពត** ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. **ឯកឧត្តម កិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | ប្រធាន |
| ២. **ឯកឧត្តម បណ្ឌិតសភាចារ្យ ណាត ប៊ុនរឿន** | រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៣. **ឯកឧត្តម ចាយ សាំងយុន** | រដ្ឋលេខាធិការ ក្រសួងការពារជាតិ | អនុប្រធាន |
| ៤. **ឯកឧត្តម ថាច់ យន** | រដ្ឋលេខាធិការ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | សមាជិក |
| ៥. **ឯកឧត្តម តន់ យ៉ាន** | រដ្ឋលេខាធិការ ក្រសួងព័ត៌មាន | សមាជិក |
| ៦. **ឯកឧត្តម ខូយ យុនហ៊្វរ** | រដ្ឋលេខាធិការ ទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៧. **ឯកឧត្តម ហោ ដារិទ្ធ** | រដ្ឋលេខាធិការ ក្រសួងផែនការ | សមាជិក |
| ៨. **លោកជំទាវ ចម និម្មល** | រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៩. **ឯកឧត្តម វ៉ាន សំអឿន** | រដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១០. **ឯកឧត្តម ម៉ាន សុត្រី** | រដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១១. **ឯកឧត្តម អ៊ុំ សុថា** | រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ១២. **ឯកឧត្តម មាន សុភា** | រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ១៣. **ឯកឧត្តម ឌី សុកផាន** | អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | សមាជិក |
| ១៤. **ឯកឧត្តម គុយ ឆាយ** | អនុរដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៥. **ឯកឧត្តម លាង សេងហាក់** | អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៦. **លោកជំទាវ កែវ ចរិយា** | អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៧. **ឯកឧត្តម អ៊ឹម ចំរុង** | អនុរដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១៨. **ឯកឧត្តម លឹម ឆាយ** | អនុរដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ១៩. **ឯកឧត្តម គួច វែងស្រ៊ុន** | អនុរដ្ឋលេខាធិការ ក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ២០. **ឯកឧត្តម ញ៉ែម សូភឿន** | អនុរដ្ឋលេខាធិការ ក្រសួងសុខាភិបាល | សមាជិក |
| ២១. **ឯកឧត្តម ប៉ុក វណ្ណធី** | អនុរដ្ឋលេខាធិការ ក្រសួងធម្មការ និងសាសនា | សមាជិក |
| ២២.**លោកជំទាវ យ៉យ នីតា** | អនុរដ្ឋលេខាធិការ ក្រសួងកិច្ចការនារី | សមាជិក |
| ២៣. **លោកជំទាវ ខៀវ សុផានី** | អនុរដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ | សមាជិក |
| ២៤. **ឯកឧត្តម អ៊ូន សុង** | អនុរដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ២៥. **ឯកឧត្តម ស៊ាង ថៃ** | អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ២៦. **ឯកឧត្តម សាន់ សារី** | អនុរដ្ឋលេខាធិការ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ២៧.**ឯកឧត្តម សួត យា** | អនុរដ្ឋលេខាធិការ ក្រសួងបរិស្ថាន | សមាជិក |
| ២៨. **ឯកឧត្តម ប៉ាង ណាត** | ទីប្រឹក្សា ក្រសួងព័ត៌មាន | សមាជិក |
| ២៩. **ឯកឧត្តម ស៊ឹម ស៊ីថា** | ទីប្រឹក្សា ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ៣០. **ឯកឧត្តម លឹម សុធា** | អគ្គនាយក នៃក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៣១. **ឯកឧត្តម សុខ សុគុណា** | ទីប្រឹក្សា និងជាអគ្គនាយករង នៃក្រសួងទេសចរណ៍ | សមាជិក |
| ៣២. **ឯកឧត្តម អ៊ឹង បូរាត** | នាយកខុទ្ទកាល័យ នៃក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៣៣. **ឯកឧត្តម អ៊ូព្រំ វីរៈ** | អគ្គនាយករង នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ៣៤. **ឯកឧត្តម ឧត្តមសេនីយ៍ឯក សរ ស៊ីនឿន** | មេបញ្ជាការរង នៃក្រសួងការពារជាតិ | សមាជិក |

៣៥. **លោកជំទាវ ឈួន ចិន្តា** អគ្គនាយករង នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម សមាជិក
៣៦. **ឯកឧត្តម បណ្ឌិត ឱម សិទ្ធី** អគ្គនាយករង នៃក្រសួងអប់រំ យុវជន និងកីឡា សមាជិក
៣៧. **ឯកឧត្តម ហូ ឈុនគ្រី** អគ្គាធិការរង នៃក្រសួងអប់រំ យុវជន និងកីឡា សមាជិក
៣៨. **លោក ម៉ក់ សុភក្ត្រា** អគ្គនាយករង នៃក្រសួងរ៉ែ និងថាមពល សមាជិក
៣៩. **លោក ជន ឌីណា** ទីប្រឹក្សា ក្រសួងឧស្សាហកម្ម និងសិប្បកម្ម សមាជិក
៤០. **លោក លឹម យូសូ** អគ្គនាយករង នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក
៤១. **លោក គង់ មុនីសុរិវៈ** អគ្គាធិការរង នៃក្រសួងមុខងារសាធារណៈ សមាជិក
៤២. **លោក សំ សារឿន** អគ្គាធិការរង នៃក្រសួងផែនការ សមាជិក
៤៣. **លោក សាន ភិរុណ្ណា** អគ្គនាយករង នៃក្រសួងពាណិជ្ជកម្ម សមាជិក
៤៤. តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក
៤៥. តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក
៤៦. តំណាងរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល សមាជិក

**ប្រការ២.-**

អភិបាលនៃគណៈអភិបាលខេត្តត្រូវបានប្រគល់ភារកិច្ចជាអនុប្រធានអចិន្ត្រៃយ៍ក្រុមការងារថ្នាក់ជាតិប្រចាំខេត្តរបស់ខ្លួន។

តួនាទី ភារកិច្ច របៀបរបបការងាររបស់ក្រុមការងារត្រូវកំណត់ដោយសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា។

ប្រធានក្រុមការងារមានសិទ្ធិសម្របសម្រួលជាមួយក្រសួង ស្ថាប័ននានា ដើម្បីចាត់មន្ត្រី ឲ្យចូលរួមក្នុងក្រុមការងារ។

**ប្រការ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន រដ្ឋបាលខេត្តកំពត និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១ កើត ខែ ផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ មីនា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

__កន្លែងទទួល:__
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*